# ប្រព័ន្ធយុត្តិធម៌កុមារ

## កែវ សុភា *

កុមារដែលឆ្លងកាត់ប្រព័ន្ធយុត្តិធម៌អាចជាជនរងគ្រោះ ជាជនប្រព្រឹត្តិល្មើសច្បាប់ និង ជាសាក្សី ហើយក្នុងករណីខ្លះអាចជាជនរងគ្រោះនិងជាជនប្រព្រឹត្តិល្មើសច្បាប់ផង ឬ ជាជនរងគ្រោះ និងសាក្សីផងដែរ នៅក្នុងបទល្មើសតែមួយ។

យោងតាមតួលេខរបស់ក្រសួងមហាផ្ទៃ និង ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា ស្ថិតិរបស់កុមាររងគ្រោះ កុមារទំនាស់នឹងច្បាប់ និង កុមារស្ថិតក្នុងស្ថានភាពប្រឈមមុខនឹងគ្រោះថ្នាក់ បង្ហាញឱ្យឃើញពីស្ថានភាពដូចតទៅ :

**ក- កុមាររងគ្រោះ :**

| ប្រភេទបទល្មើស | ចំនួនករណីសរុប | | ចំនួនជនរងគ្រោះ | | ចំនួនជនរងគ្រោះជាកុមារ | |
|---|---|---|---|---|---|---|
| | 2007 | 2008 | 2007 | 2008 | 2007 | 2008 |
| កេងប្រវ័ញ្ចផ្លូវភេទ | 20 | 38 | 131 | 439 | 7 | 49 |
| ជួញដូរនៅក្នុងប្រទេសកម្ពុជា | 16 | 21 | 31 | 34 | 17 | 19 |
| ជួញដូរឆ្លងដែន | 12 | 6 | 116 | 15 | 3 | 3 |
| រូបភាពនិងសម្ភារៈអាសអាភាស | 9 | 11 | 0 | 37 | 0 | 6 |
| រំលោភសេពសន្ថវៈ | 282 | 127 | 258 | 138 | 141 | 51 |
| រំលោភសេពសន្ថវៈ និង សំលាប់ | 15 | 2 | 15 | 2 | 11 | 2 |
| ប៉ុនប៉ងរំលោភសេពសន្ថវៈ | 87 | 51 | 83 | 57 | 53 | 45 |
| បៀតបៀនកេរ្តិ៍ខ្មាស់ | 25 | 30 | 19 | 31 | 15 | 15 |
| អំពើអនាចារ | 20 | 69 | 25 | 84 | 25 | 84 |
| អំពើហឹង្សាក្នុងគ្រួសារ | 90 | 81 | 91 | 97 | 0 | 3 |
| **សរុប** | **576** | **436** | **769** | **934** | **272** | **277** |

* លោក កែវ សុភា នាមដើម កែវ សុគា ជាមេធាវីនៃគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ហើយកំពុងបំពេញការងារជាមន្ត្រី។។។ នៅមូលនិធិអង្គការ សហប្រជាជាតិដើម្បី ទ្រទ្រង់កុមារ និងគ្រាអាសន្ន (យូនីសែហ្វ)។ លោកបញ្ចប់ការសិក្សានិងទទួលបាន បរិញ្ញាប័ត្រច្បាប់ពិសាកលវិទ្យាល័យច្បាប់និងសេដ្ឋកិច្ច។

យោងតាមតួលេខនេះ ចំនួនកុមារដែលរងគ្រោះ ដោយសារការរំលោភច្បាប់មានដល់ទៅ ៣៥% ក្នុងឆ្នាំ ២០០៧ និង ២៩% នៃចំនួនជនរងគ្រោះពីអំពើល្មើសដូចគ្នា។ តួលេខនេះបញ្ជាក់ឱ្យឃើញថា បទល្មើសដែលប្រព្រឹត្តទៅលើកុមារមានចំនួនគួរឱ្យព្រួយបារម្ភ។ ការធ្វើឱ្យកុមារធ្លាក់ខ្លួនរងគ្រោះដោយសារ បទល្មើសមានផលវិបាកដល់ការអភិវឌ្ឍន៍ផ្នែករូបរាងកាយ ស្មារតីនិង បញ្ញា។

ខ- កុមារទំនាស់នឹងច្បាប់ និង កុមារស្ថិតក្នុងស្ថានភាពប្រឈមមុខនឹងគ្រោះថ្នាក់ គិតត្រឹមខែមីនា ឆ្នាំ ២០០៩ :

| ខេត្ត-រាជធានី | ចំនួនសរុប | ទណ្ឌិត | ពិរុទ្ធជន | ចូលថ្មី | ដោះលែង ឬ ធ្វើសមាហរណកម្ម | កុមារតាមម្តាយ ដែលជាប់ពន្ធនាគារ |
|---|---|---|---|---|---|---|
| មណ្ឌលអប់រំព្រៃស | ៤១៦ | ៣១០ | ១០៦ | ២៩ | ២៤ | ១៦ |
| ខេត្តកណ្តាល | ៧១ | ៣៨ | ៣៣ | ១០ | ០៨ | ០៦ |
| ខេត្តសៀមរាប | ៨៥ | ៦០ | ២៥ | ១១ | ១៤ | ០៧ |
| ខេត្តបាត់ដំបង | ៤២ | ២៦ | ១៦ | ១០ | ០៧ | ០៦ |
| មណ្ឌលចោមចៅ | ១៤ | ០ | ០ | ០១ | ០៣ | ០ |
| **សរុប** | **៦២៨** | **៤៣៤** | **១៨០** | **៦១** | **៥៦** | **៣៥** |

កុមារមានចំណេះដឹងនិងការវិនិច្ឆ័យមានកំរិត មានអារម្មណ៍និងការយល់ឃើញ ខុសប្លែកពីនីតិជន និង មានភាពងាយរងគ្រោះជាងនីតិជន ដូច្នេះទាមទារឱ្យមានប្រព័ន្ធយុត្តិធម៌មួយដែលមានលក្ខណៈកុមារមេត្រី ពោលគឺឱ្យកុមារអាចចូលរួមផ្តល់ឬរកភាពយុត្តិធម៌បាន មានការគិតគូរដល់តំរូវការពិសេសរបស់កុមារនីមួយៗ និងមានវិធីសាស្ត្រដោយឡែកក្នុងការធ្វើការជាមួយកុមារនៅក្នុងប្រព័ន្ធយុត្តិធម៌ដើម្បីផ្តល់សេវា និង ការពារកុមារឱ្យបានប្រសើរឡើង។

ប្រព័ន្ធយុត្តិធម៌កុមារ សំដៅដល់ប្រព័ន្ធយុត្តិធម៌ដែលទ្រទ្រង់ដល់កុមារជាជនរងគ្រោះ កុមារប្រព្រឹត្តល្មើសច្បាប់ និង កុមារជាសាក្សី។ ជាទូទៅ មិនខុសពីនីតិជនជាច្រើននៅក្នុងព្រះរាជាណាចក្រកម្ពុជានោះទេ កុមារប្រព្រឹត្តិល្មើសច្បាប់ដោយមិនដឹងថាច្បាប់ជាអ្វីនោះទេ។ ហេតុនេះហើយបានជានៅក្នុងទស្សនៈនៃច្បាប់

សម័យទំនើបយើងហៅកុមារបែបនេះថាជា "កុមារទំនាស់នឹងច្បាប់" តែមិនហៅថា កុមារល្មើសច្បាប់នោះ ទេ ព្រោះកុមារមិនមានការយល់ដឹងអំពីសញ្ញាណនៃអំពើឬការខកខានដែលច្បាប់ហាមនិងដាក់ទោស មានចំណេះដឹងតិចតួចស្តួចស្តើងដោយសារខ្លួនទើបតែមានអត្ថិភាពនៅក្នុងសង្គម មិនមានសមត្ថភាពក្នុងការបែងចែកខុសត្រូវបានពេញលេញ និង ទទួលឥទ្ធិពលអវិជ្ជមានជាច្រើនពីសង្គម ជាពិសេសពីសំណាក់នីតិជនដែលបំពានច្បាប់យ៉ាងចំហនិងគ្មានកោតក្រែង ។

ទោះបីជាយើងខំពន្យល់ជាភាសាសំរាយអំពីច្បាប់យ៉ាងណាក៏ដោយ ក៏អនីតិជនមិនអាចយល់បានច្បាស់ថា អ្វីជាច្បាប់នោះឡើយ ។ ដើម្បីងាយយល់ដល់ទស្សនាទាននៃកុមារ សូមសាកល្បងពិនិត្យនិយមន័យ ដែលអង្គការឯកទេសពីរនៃអង្គការសហប្រជាជាតិគឺយូនីសែហ្វ និងការិយាល័យអង្គការសហប្រជាជាតិទាក់ទងនឹងគ្រឿងញៀននិងឧក្រិដ្ឋកម្មដែលឱ្យនិយមន័យអំពីច្បាប់ថា "*ច្បាប់គឺជាវិធានឬក្បួនខ្នាតដែលជនគ្រប់រូបត្រូវអនុវត្តតាមដើម្បីឱ្យមនុស្សអាចគោរពគ្នាទៅវិញទៅមក គោរពសិទ្ធិសេរីភាពគ្នារបស់មនុស្សគ្រប់រូប និង រស់នៅជាមួយគ្នាប្រកបដោយសុខសន្តិភាព ។ មានច្បាប់ជាច្រើនប្រភេទ ហើយប្រភេទទាំងអស់នោះ រួមគ្នាជួយឱ្យមនុស្សធ្វើអំពើត្រឹមត្រូវ*"[១] ។ យើងសាកល្បងសួរខ្លួនឯងថា ប្រសិនបើយើងមិនមែនជាមេធាវី ចៅក្រម ព្រះរាជអាជ្ញា ឬមន្ត្រីដែលឆ្លងកាត់ការ បណ្តុះបណ្តាល ផ្នែកច្បាប់ ឬ បំពេញតួនាទីដឹកនាំ តើយើងយល់ដឹងច្បាស់ថាអ្វីទៅជាច្បាប់ អ្វីខ្លះជាអំពើដែលច្បាប់ហាមឃាត់ បានយ៉ាងទូលំទូលាយដូចម្តេចកើត? ដូច្នេះបើពិចារណាអំពីធាតុអត្តនោម័ត នៅក្នុងបណ្តាធាតុផ្សំនៃបទល្មើស ជាពិសេសសញ្ញាណនៃច្បាប់និងការដឹងខុសត្រូវរបស់កុមារ ពិតជាមិនគួរអនុវត្តវិធានការតឹងរ៉ឹងហួសពីកំរិតយល់ដឹងនោះឡើយ ។

ប្រព័ន្ធយុត្តិធម៌កុមាររួមមានសមាសភាគដូចតទៅ :

១/ ស្ថាប័នយុត្តិធម៌ និង ស្ថាប័នអនុវត្តច្បាប់ដែលដំណើរការដោយរដ្ឋ ក្នុងនោះរួមមានអំណាចអយ្យការ អង្គស៊ើបសួរ(ចៅក្រមស៊ើបសួរ) តុលាការ (ទាំងរឿងក្តីព្រហ្មទណ្ឌ ទាំងរឿងក្តីរដ្ឋប្បវេណី) ក្រសួងយុត្តិធម៌ (រៀបចំច្បាប់និងបទដ្ឋាននានា) នគរបាល កងរាជអាវុធហត្ថ ពន្ធនាគារ និង

២/ យន្តការយុត្តិធម៌ដែលមិនដំណើរការដោយរដ្ឋ(អាចបង្កើតឬមិនបង្កើតដោយរដ្ឋ) ដូចជាទំនៀមទំលាប់ប្រពៃណី សាសនា និង យន្តការមិនផ្លូវការផ្សេងទៀតដែលដោះស្រាយវិវាទនៅតាមសហគមន៍ឃុំ/សង្កាត់ និង នៅតាមភូមិ ។

---

[1] សូមដាក់ឈ្មោះឯកសារយោងនៅត្រង់នេះ

មេធាវីស្ថិតនៅក្នុងចំណុចទី១ និង ទី២ ខាងលើទៅតាមស្ថានភាពចាំបាច់។

ក្រៅពីនេះ ប្រព័ន្ធសុខុមាលភាពសង្គមដែលក្នុងនោះរួមមានច្បាប់និងបទដ្ឋានក្រោមច្បាប់ដែលផ្តល់នូវការការពារផ្នែកសង្គម សេវាសង្គមកិច្ច និង អ្នកជំនាញខាងកិច្ចការសង្គមកិច្ច ក៏មានតួនាទីសំខាន់ខ្លាំងណាស់ដែរនៅក្នុងប្រព័ន្ធយុត្តិធមិកុមារ។

នៅពេលកុមារពេីបប្រទះនឹងប្រព័ន្ធយុត្តិធមិ កុមារគិតគូរអំពីប្រព័ន្ធនេះក្នុងរូបភាពមួយសាំញ៉ុំជាទីបំផុត។ សូម្បីតែអ្នកណាជាចៅក្រម ព្រះរាជអាជ្ញា មេធាវី និង ក្រឡាបញ្ជី ហើយអ្នកទាំងនោះមានតួនាទីបែបណានោះ ក៏កុមារមិនយល់ដែរ។ កុមារមួយចំនួនសួរថាហេតុអ្វីបានជាគេតំរូវឱ្យមនុស្សមួយចំនួនឈរមុខច្រកសេះ ហើយក្រចកសេះមានអត្ថន័យយ៉ាងណា ជាអាទិ៍។

តាមការស្រាវជ្រាវនានាបានបង្ហាញឱ្យឃើញថា នៅមុនពេលជំនុំជំរះ អារម្មណ៏របស់កុមារមានជិតដាមនៅជាប់នឹងខ្លួន ដោយគិតថា [២]:

- តុលាការជាកន្លែងមួយដែលគួរឱ្យភ័យខ្លាច។ ចៅក្រម និង មេធាវីនឹងសំឡុត ខ្លួន, ខ្លួនមិនដែលឡើង តុលាការពីមុនមក, តុលាការនឹងយកខ្លួនទៅដាក់គុកជាដើម ។ល។
- មានការភ័យខ្លាច ដោយសារចៅក្រម និង មេធាវីនិយាយឮខ្លាំង ឬមានមនុស្សច្រើនចូលរួមស្តាប់ក្នុងនោះមានទាំងជនល្មើស និង នគរបាលផងដែរ។
- មេធាវីកាច ជាពិសេសមេធាវីរបស់ជនជាប់ចោទ។
- តុលាការ/ចៅក្រម អាចនឹងវាយខ្លួន ប្រសិនបើខ្លួនមិននិយាយការពិត។
- តុលាការជាកន្លែងមិនល្អ តុលាការអាចជាកន្លែងមិនស្អាតស្អំ ព្រួយបារម្ភថាសាលក្រមដែលតុលាការនឹងចេញមិនល្អសំរាប់ខ្លួន។
- ខ្លួនមានសង្ឃឹមតិច១ ថានឹងឈ្នះក្តីថាតុលាការនឹងរកយុត្តិធមិឱ្យខ្លួន។
- កុមារដែលធ្លាប់ឡើងតុលាការ ជាពិសេសកុមារទំនាស់នឹងច្បាប់ដែលធ្លាប់ឡើងតុលាការច្រើនតែមានអារម្មណ៏ធម្មតា។ ខ្លះយល់ថាខ្លួនមិនបានធ្វើអ្វីខុស ដូច្នេះខ្លួនមិនភ័យខ្លាច ។ល។

---

[2] បើមានឯកសារណាបញ្ជាក់ពិការរកឃើញខាងលើសូមយោងឯកសារនោះនៅត្រង់នេះ។

- កុមារបែកញើសតាមបាតដៃ និង បាតជើង និង ដេកមិនលក់ពេញមួយយប់ គិតថាតើខ្លួនគួរនិយាយអ្វីខ្លះនៅពេលសវនាការ។ កុមារត្រជាក់ដៃជើង និង ស្ពឹកជើង ហើយចង់ឱ្យមានអ្នកអង្គុយក្បែរដើម្បី លើកទឹកចិត្ត។ ខ្លះទៀតឈឺក្បាល...ញ័រខ្លួន...ញ័រដៃ...យំ...ឃ្លាន ។ល។

ការស្រាវជ្រាវដដែលនោះ ក៏បង្ហាញឱ្យឃើញផងដែរថា នៅពេលសវនាការ កុមារយល់ឃើញ មានអារម្មណ៍ និង អាការៈដូចតទៅ :

- ភ័យតក់ស្លុតខ្លាំងព្រោះមិនអាចឆ្លើយនឹងសំណួរ មានមនុស្សច្រើននៅក្នុងបន្ទប់ តក់ស្លុតពេលជនល្មើសឈរជិតឬសម្លឹងមករកខ្លួន។
- ទឹកមុខចៅក្រមបង្ហាញថាគាត់មិនជឿសំដីខ្លួនជាអនីតិជន ចៅក្រមនិងក្រឡាបញ្ជីមានទឹកមុខកាច
- តក់ស្លុតនៅពេលមេធាវីរបស់ជនជាប់ចោទនិយាយខ្លាំងៗមកកាន់ខ្លួនឬសួរសំណួរពិបាកយល់
- ព្រួយបារម្ភខ្លាចការជំនុំជំរះបន្តទៅថ្ងៃបន្ទាប់ ព្រោះខ្លួនយល់ថាការបន្តគឺជាសភាពការលំបាក
- ភ័យមិនហ៊ានមើលមុខចៅក្រម និង មេធាវី ភ័យខ្លាំងដោយសារត្រូវនិយាយរឿងដែលកើតឡើងចំពោះខ្លួន មានអារម្មណ៍ថាគាំងនិយាយមិនចេញ
- ភ័យនៅពេលចៅក្រមហៅចំឈ្មោះឱ្យក្រោកឈរដើម្បីសួរយកចម្លើយ ព្រោះខ្លួននិយាយមិនសូវញនិងមិនសូវច្បាស់ និងខ្លាចទទួលការស្តីបន្ទោស
- ខ្លាចអ្វីៗទាំងអស់ដែលមាននៅក្នុងបន្ទប់ជំនុំជំរះ ខ្លាចអ្វីមួយដែលមិនបានរំពឹងទុកកើតឡើងចំពោះខ្លួន ភ័យខ្លាំងនៅពេលចៅក្រមគោះតុឈើនឹងញញួរ
- មានអារម្មណ៍កើតទុក្ខ និងយំនៅពេលម្តាយឈរនៅមុខក្រចកសេះ (ម្តាយជាជនល្មើស)
- មិនភ័យខ្លាច ប្រសិនបើមាននីតិជនអម (អ្នកសង្គមកិច្ច ឪពុកម្តាយ ឬ នីតិជនសមស្រប)
- មិនដឹងថាតើត្រូវឈរនៅកន្លែងណានៅពេលតុលាការសួរយកចំលើយ
- តុលាការជាកន្លែងមួយដែលគួរឱ្យភ័យខ្លាចជាងការគិតរបស់ខ្លួនទៅទៀត។ ពេលមេធាវីរបស់ខ្លួននិយាយប្រាប់អំពីតុលាការ ខ្លួនមិនខ្លាច តែពេលទៅដល់និងមើលឃើញផ្ទាល់ភ្នែកយល់ថាចៅក្រមនិងមេធាវីគួរឱ្យខ្លាច
- ខ្លះយល់ថាតុលាការមិនអាក្រក់ដូចខ្លួនបានគិតនោះទេ តុលាការមិនបានសំឡុតបំភ័យខ្លួននោះទេ ចៅក្រមនិងមេធាវីនិយាយមានការគួរសមនៅពេលសួរសំណួរ។ ចៅក្រមនិងមេធាវីលើកទឹកចិត្តមិនឱ្យខ្លួនភ័យខ្លាចនិងនិយាយការពិត។

- ខ្លាចជនល្មើសទទួលទោសស្រាល ហើយពេលចេញមកវិញធ្វើបាបគ្រួសារខ្លួន
- ចង់ដឹងពីសាលក្រម
- មិនយល់ពីសាលក្រមដែលបានប្រកាស
- តុលាការល្អ កន្លែងអង្គុយល្អ ហើយចៅក្រមក៏ល្អដែរ តែមើលមុខទៅគួរឱ្យខ្លាច។
- កុមារមួយចំនួនគិតថាបន្ទប់សវនាការរញ៉ីរញ៉ៃគ្មានសន្តាប់ធ្នាប់ ខ្វះអនាម័យ មានមនុស្សច្រើន ក្តៅនិងពិបាកដកដង្ហើម (ចំពោះតុលាការមួយចំនួន)
- ញ័រដៃជើងនៅពេលចៅក្រមនិយាយឮ និងខ្លាំងៗទៅកាន់ជនល្មើស
- មានអារម្មណ៍ចង់លោះព្រលឹងនៅពេលជនល្មើសនិយាយកុហក និង ចង់និយាយទៅកាន់ជនល្មើស
- បេះដូងដើរលឿន ត្រជាក់ដៃជើង បែកញើសដៃជើង ញ័រដៃជើង ស្ពឹកដៃជើង មានអារម្មណ៍ថាប្រហោងពោះ មានអារម្មណ៍ថាត្រជាក់ខ្លួន បបូរមាត់កំរើកមិនរួច ឈឺក្បាល ចង់គ្រុន និង ឡើងកំដៅខ្លួន ញ័រជើងឈរមិនចង់កើត
- កុមារខ្លះចង់ទៅបន្ទប់ទឹក និង ឡើងកំដៅខ្លួន ។ល។

បញ្ហាខាងលើគ្រាន់តែជាការសង្ខេបប៉ុណ្ណោះ។ ក្រៅពីកុមារត្រូវពើបប្រទះការលំបាកផ្នែកអារម្មណ៍ ផ្លូវចិត្ត និង ផ្លូវកាយ នៅមុនពេលឡើងតុលាការ ពេលនៅតុលាការ និង ក្រោយពេលជំនុំជំរះ កុមារជួបការលំបាកជាច្រើនទៀតដូចជាការសម្ភាសន៍ច្រើនដង ការរើសអើង ការទំលាក់កំហុសពីគ្រួសារនិងសហគមន៍ ការលំបាកផ្នែកសេដ្ឋកិច្ច ការមិនទទួលបាននូវប្រព័ន្ធសុខុមាលភាពមួយដែលដំណើរការពិតៗ ។ល។ មានករណីជាច្រើនដែលបង្ហាញឱ្យឃើញថាសូម្បីតែសមាជិកគ្រួសាររបស់កុមាររងគ្រោះក៏ទទួលរងនូវការលំបាកផ្នែកសេដ្ឋកិច្ច ព្រួយបារម្ភពីសន្តិសុខផ្ទាល់ខ្លួន និងការប៉ះទង្គិចផ្លូវចិត្តធ្ងន់ធ្ងរផងដែរពីផលវិបាកនៃបទល្មើស។

ដោយឡែកគ្រួសាររបស់កុមារទំនាស់នឹងច្បាប់ក៏ពើបប្រទះនឹងបញ្ហាប្រហាក់ប្រហែលគ្នា។ ជាទូទៅយើងសំគាល់ឃើញថា ក្រោយពីរឿងក្តីត្រូវបានបញ្ចប់ គ្រួសាររបស់កុមារជំពាក់បំណុលគេកាន់តែច្រើន និង មិនសូវមានជំនឿលើប្រព័ន្ធច្បាប់ និង តុលាការ។

រដ្ឋជាច្រើនមិនបានចាត់ទុកថាកុមារទំនាស់នឹងច្បាប់ស្ថិតនៅក្នុងរបៀបវារៈខ្ពស់របស់ខ្លួននោះទេ ឬ និយាយម៉្យាងទៀតថា "កុមារទាំងនោះជាកូនដែលរដ្ឋមិនចង់ទទួលខុសត្រូវ "[3] ដោយមានកត្តាសត្យានុម័ត កត្តាអត្តនោម័ត និង កត្តាប្រវត្តិសាស្ត្រដោយឡែក១របស់ខ្លួន ។

ជុំវិញបញ្ហាយុត្តិធម៌អនីតិជនទំនាស់នឹងច្បាប់ មានកិច្ចការជាច្រើនដែលត្រូវកែលំអ ដូចជា អំពើហឹង្សាលើកុមារទំនាស់នឹងច្បាប់ ការប្រើប្រាស់វិធានការឃុំខ្លួនបណ្តោះអាសន្នលក្ខខណ្ឌនៃការឃុំខ្លួន និង រយៈពេលឃុំខ្លួនយូរ ។ បញ្ហាទាំងនេះនៅតែជាបញ្ហាកង្វល់នៅក្នុងប្រទេសជាច្រើននៅលើពិភពលោក រួមទាំង ព្រះរាជាណាចក្រកម្ពុជាផងដែរ ។

ជាទូទៅមានការខ្វះខាតទិន្នន័យរបស់រដ្ឋ ទាក់ទងនឹងកិច្ចការយុត្តិធម៌អនីតិជនទំនាស់នឹង ច្បាប់ ដូចជារយៈពេលឃុំខ្លួនបណ្តោះអាសន្ន ទោសដែលកុមារត្រូវរង ប្រភេទបទល្មើសដែលកុមារប្រព្រឹត្ត ។ល ។ កង្វះខាតទាំងនេះកើតមានឡើង ម៉្យាងដោយសារកិច្ចការយុត្តិធម៌អនីតិជនទំនាស់នឹងច្បាប់មិនមែនជា អាទិភាពរបស់រដ្ឋ កង្វះការទទួលខុសត្រូវ និង ចំណាប់អារម្មណ៍របស់មន្ត្រីដែលជាប្រភព ដើមនៃទិន្នន័យ ជាពិសេសមន្ត្រីតុលាការ កង្វះខាតមន្ត្រីដែលទទួលខុសត្រូវដោយឡែកលើការងារ ពត៌មានវិទ្យា ស្ថិតិ និង រដ្ឋបាល និង ការចាត់ការកិច្ចការយុត្តិធម៌ ដោយគ្មានយុទ្ធសាស្ត្រ និងផែនការច្បាស់លាស់ ។ សូម្បីតែ នៅប្រទេសជាច្រើននៅតំបន់អឺរ៉ុប ដែលជាប្រទេសមានធនធានសេដ្ឋកិច្ចគ្រប់គ្រាន់សំរាប់អនុវត្តច្បាប់ និង គោលនយោបាយទាក់ទងនឹងសិទ្ធិរបស់អនីតិជនទំនាស់នឹងច្បាប់ក្តី ក៏ប្រទេសទាំងនោះបែរជាប្រកាន់យក នូវគោលនយោបាយមួយចំនួន ដែលមានចរិតជាការបង្ក្រាបលើមនុស្សវ័យក្មេង ជាជាងការអប់រំកែប្រែ ជាពិសេសចំពោះបទល្មើសព្រហ្មទណ្ឌធ្ងន់១និងអ្នកមិនរាងចាល ដែលការណ៍នោះមានករណីខ្លះផ្ទុយនឹងបទដ្ឋាន អន្តរជាតិនិងការអនុវត្តល្អដែលកំពុងជំរុញលើកទឹកចិត្តដោយអង្គការជំនាញនៃអង្គការសហប្រជាជាតិ ។

បទដ្ឋានអន្តរជាតិសំខាន់១ទាក់ទងនឹងកុមារនៅក្នុងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ រួមមានជាអាទិ៍ :

១- អនុសញ្ញាស្តីពីសិទ្ធិកុមារ

២- គោលការណ៍ណែនាំនៃអង្គការសហប្រជាជាតិស្តីពីការបង្ការអនីតិជនប្រព្រឹត្តិបទល្មើស

៣- វិធានបទដ្ឋានអប្បរមានៃអង្គការសហប្រជាជាតិស្តីពីការគ្រប់គ្រងយុត្តិធម៌អនីតិជនទំនាស់នឹងច្បាប់

---

[3] [Name of Author], Legislation to Action:,Trends in Juvenile Justice Across 15 Countries, (Defence for Children International, Geneva, 2007), page [xx].

៤- វិធាននៃអង្គការសហប្រជាជាតិស្តីពីការការពារអនីតិជនដែលត្រូវបានដកហូតសេរីភាព

៥- វិធានបទដ្ឋានអប្បរមានៃអង្គការសហប្រជាជាតិស្តីពីវិធានការមិនឃុំឃាំងខ្លួន

៦- គោលការណ៍ណែនាំនៃអង្គការសហប្រជាជាតិស្តីពីវិធានការចំពោះកុមារនៅក្នុងព្រ័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ

៧- គោលការណ៍មូលដ្ឋាននៃអង្គការសហប្រជាជាតិស្តីពីការប្រើប្រាស់កម្មវិធីយុត្តិធម៌ដើម្បីឱ្យមានការសះជា

៨- គោលការណ៍ណែនាំនៃអង្គការសហប្រជាជាតិស្តីពីកិច្ចការយុត្តិធម៌សំរាប់កុមាររងគ្រោះ និង កុមារជាសាក្សីនៃបទល្មើសព្រហ្មទណ្ឌ។

វិធានខាងលើរួមមានគោលការណ៍ច្បាប់ជាច្រើនទាក់ទងនឹងវិស័យយុត្តិធម៌កុមារ (កុមាររងគ្រោះ និង កុមារទំនាស់នឹងច្បាប់)។ ដោយឡែក ចំពោះកុមារទំនាស់នឹងច្បាប់ ព្រះរាជាណាចក្រកម្ពុជាបានប្រកាន់យកនូវគោលការណ៍សំខាន់ៗ មួយចំនួនដែលមានប្រភពចេញពីបទដ្ឋានអន្តរជាតិសំខាន់ៗខាងលើ និង បានដាក់បញ្ចូលគោលការណ៍ទាំងនោះទៅក្នុងច្បាប់របស់ខ្លួន (ច្បាប់ស្តីពីអនីតិជនទំនាស់នឹងច្បាប់)។ គោលការណ៍ទាំងនោះរួមមានជាអាទិ៍:

**ក**- ក្នុងគ្រប់សកម្មភាពទាក់ទងនឹងអនីតិជនទំនាស់នឹងច្បាប់ត្រូវពិចារណាឧត្តមប្រយោជន៍របស់អនីតិជនទំនាស់នឹងច្បាប់ និងត្រូវយកចិត្តទុកដាក់ជាពិសេសចំពោះសិទ្ធិមានជីវិត និង សិទ្ធិរស់រាន និងការរីកចំរើនលូតលាស់ជាអតិបរមា។

**ខ**-អនីតិជនទំនាស់នឹងច្បាប់ទាំងអស់ត្រូវទទួលបាននូវសិទ្ធិដែលមានចែងនៅក្នុងច្បាប់ស្តីពីអនីតិជនទំនាស់នឹងច្បាប់ ដោយមិនមានការរើសអើងអ្វីទាំងអស់ ។

**គ**-អនីតិជនទំនាស់នឹងច្បាប់ទាំងអស់ត្រូវបានផ្តល់ឱកាសឱ្យសំដែងមតិដោយសេរីក្នុងគ្រប់បញ្ហាទាំងអស់ដែលទាក់ទងនឹងខ្លួន ហើយទស្សនៈនោះត្រូវបានយកទៅពិចារណា ថ្លឹងថ្លែងស្របទៅតាមអាយុ និង កំរិតយល់ដឹងរបស់អនីតិជន។

**ឃ**-រាល់នីតិវិធីទាំងអស់ត្រូវប្រព្រឹត្តទៅក្នុងលក្ខណៈ ងាយស្រួលដល់អនីតិជន និង ក្នុងភាសាដែលអនីតិជនអាចយល់បាន ។

**ង**-អនីតិជនគ្រប់រូបត្រូវបានផ្តល់នូវការប្រព្រឹត្តប្រកបដោយមនុស្សធម៌ និងយុត្តិធម៌ ដែលលើកស្ទួយនូវសេចក្តីថ្លៃថ្នូរ និង តម្លៃរបស់អនីតិជន ។ អនីតិជនត្រូវបានផ្តល់នូវការការពារពិសេសនៅក្នុង

ប្រព័ន្ធយុត្តិធម៌ ហើយត្រូវធានានូវសុខុមាលភាពរបស់អនីតិជន ។ ខ្នោះដៃ និងខ្នោះច្រវ៉ាក់ មិនត្រូវប្រើប្រាស់នោះឡើយលុះត្រាមានករណីចាំបាច់ ហើយជម្រើសនៃវិធានទាំងឡាយត្រូវបានប្រើអស់ ។

**ច**- នៅគ្រប់ដំណាក់កាលនៃដំណើរការនីតិវិធី អនីតិជនត្រូវ បានប្រព្រឹត្តក្នុងលក្ខណៈមួយ ដែលលើកស្ទួយការអភិវឌ្ឍន៍ចរិតលក្ខណៈ និង ការទទួលខុសត្រូវផ្នែកខាងសីលធម៌របស់ខ្លួនជាពលរដ្ឋមួយរូប និងដែលសម្រួលដល់ការធ្វើសមាហរណកម្ម និងការបន្តតួនាទីសកម្មនៅ ក្នុងសង្គម ។

**ឆ**- ការឆ្លើយតបរបស់អាជ្ញាធរនានាចំពោះអនីតិជនទំនាស់នឹងច្បាប់ ជានិច្ចជាកាលត្រូវសមាមាត្រមិនត្រឹមតែទៅនឹងទម្ងន់នៃបទល្មើសទេ តែអាស្រ័យទៅលើកាលៈទេសៈ អាយុ និងសេចក្តីត្រូវការផ្ទាល់ខ្លួនរបស់អនីតិជនផងដែរ ។

**ជ**-ការចាប់ខ្លួន ការឃុំខ្លួន និង ការដាក់ពន្ធនាគារអនីតិជន អនុវត្តសម្រាប់តែវិធានការចុងក្រោយ ។

**ឈ**- ការប្រើប្រាស់កម្មវិធីតាមសហគមន៍ និង កម្មវិធីសមស្របផ្សេងៗសម្រាប់បង្វែរអនីតិជនចេញពីនីតិវិធីតុលាការ ត្រូវបានពិចារណាក្នុងរាល់ករណីសមស្រប ។

**ញ**- ករណីការបង្វែរមិនមានលក្ខណៈសមស្រប ការឃុំខ្លួនអនីតិជនត្រូវប្រព្រឹត្តទៅសម្រាប់តែរយៈពេលចាំបាច់ដែលខ្លីបំផុត ហើយត្រូវបំបែកអនីតិជនពីមនុស្សពេញវ័យ ។

**ដ**- ការបង្គាប់ឱ្យដាក់អនីតិជនក្នុងស្ថាប័ន ឬមណ្ឌល ធ្វើឡើងតែក្នុងករណីពុំមានមធ្យោបាយជំនួសសមស្របប៉ុណ្ណោះ ។ ក្នុងករណីបែបនេះ ត្រូវផ្តល់ការថែទាំ ការការពារ និង ជំនួយឧបត្ថម្ភផ្នែកអប់រំ ផ្នែកចិត្តសាស្ត្រ និងផ្នែកវេជ្ជសាស្ត្រតាមការចាំបាច់ ដើម្បីសម្រួលដល់ការស្តារនីតិសម្បទា និង ការធ្វើសមាហរណកម្មសង្គមរបស់អនីតិជន ។

**ឋ**- ការប្រកាសដកសិទ្ធិសេរីភាពអនីតិជន ធ្វើឡើងសម្រាប់តែករណីចាំបាច់បំផុត ដូចជាករណីប្រព្រឹត្តបទល្មើសធ្ងន់ធ្ងរដែលពាក់ព័ន្ធនឹងអំពើហឹង្សាប្រឆាំងនឹងបុគ្គល ឬ ការប្រព្រឹត្តបទល្មើសធ្ងន់ធ្ងរផ្សេងទៀត និងធ្វើឡើងតែក្នុងករណីពុំមានការសម្រេចសមស្របផ្សេងទៀត ។

**ឲ**- ការដាក់ពន្ធនាគារអស់មួយជីវិត ការដាក់ទណ្ឌកម្មលើរូបរាងកាយ និង ការប្រព្រឹត្ត ឬ ការដាក់ទណ្ឌកម្មឃោរឃៅ ឬ បន្ទាបបន្ថោក អនីតិជនត្រូវហាមឃាត់ ។

ជាគោលការណ៍ នៅពេលមានច្បាប់ពិសេស ឧទាហរណ៍ដូចជាច្បាប់ស្តីពីការការពារកុមារ ច្បាប់ស្តីពីសុខុមាលភាពកុមារ ច្បាប់ស្តីពីសុំកូនអន្តរប្រទេស និង ច្បាប់ស្តីពីអនីតិជនទំនាស់នឹងច្បាប់ យើង

អនុវត្តបទបញ្ញត្តិនៃច្បាប់ពិសេស ហើយអ្វីដែលមិនមានបញ្ញត្តិក្នុងច្បាប់ពិសេស យើងអនុវត្តវិធានទូទៅ ដូចជាក្រមព្រហ្មទណ្ឌ ក្រមនីតិវិធីព្រហ្មទណ្ឌ ក្រមរដ្ឋប្បវេណី និងក្រមនីតិវិធីរដ្ឋប្បវេណី។ ករណីបទបញ្ញត្តិនៃច្បាប់ពិសេស និង វិធានទូទៅមានភាពផ្ទុយគ្នា វិធាននៃច្បាប់ពិសេសទាក់ទងកិច្ចការយុត្តិធម៌កុមារនឹងមានឧត្តមានុភាពលើវិធានទូទៅ។

ប្រទេសនានាប្រកាន់យកក្របខ័ណ្ឌច្បាប់ទាក់ទងនឹងកិច្ចការយុត្តិធម៌អនីតិជនទំនាស់នឹងច្បាប់ខុសៗគ្នាអាស្រ័យលើគោលនយោបាយ និង បរិបទដោយឡែករបស់ប្រទេសខ្លួន។ ក៏ប៉ុន្តែជារួម យើងឃើញមានការអនុវត្ត ៣ បែបដូចខាងក្រោម :

១- មានបទប្បញ្ញត្តិពិសេស ឬ ជំពូកដោយឡែកស្តីពីយុត្តិធម៌អនីតិជនទំនាស់នឹងច្បាប់នៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ និង ក្រមព្រហ្មទណ្ឌ

២- មានផ្នែកដោយឡែកនៅក្នុងច្បាប់ស្តីពីការការពារកុមារដ៏ទូលំទូលាយមួយដែលចែងគ្របដណ្តប់អំពីសិទ្ធិនានារបស់កុមារ

៣- មានក្រម/ច្បាប់ដោយឡែក និង ទូលំទូលាយស្តីពីយុត្តិធម៌អនីតិជនទំនាស់នឹងច្បាប់ ដែលដោះស្រាយតែបញ្ហាទាក់ទងនឹងអនីតិជនទំនាស់នឹងច្បាប់។

ពិភពលោកទំនងជាមាននិន្នាការឆ្ពោះទៅរកការបង្កើតក្រម/ច្បាប់ដោយឡែក និង ទូលំទូលាយស្តីពីយុត្តិធម៌អនីតិជនទំនាស់នឹងច្បាប់។ ដោយឡែកប្រទេសដែលទទួលឥទ្ធិពលពីច្បាប់បែបស៊ីវិល ដូចជាចិន ឥណ្ឌូណេស៊ី ឡាវ ម៉ុងហ្គោលី និង វៀតណាម ច្បាប់មានទំនោរខ្លី និងបញ្ញត្តិទូទៅ ដោយត្រូវណែនាំអនុវត្តបន្ថែមដោយបទដ្ឋានក្រោមច្បាប់។ ក៏ប៉ុន្តែការបើកសិទ្ធិទូលំទូលាយពេកឱ្យអង្គនៃនីតិប្រតិបត្តិចេញបទដ្ឋានក្រោមច្បាប់ ដែលករណីខ្លះមានចរិតជាច្បាប់ ច្រើនតែបណ្តាលឱ្យអង្គតុលាការមិនសូវមានសេចក្តីក្លាហាននឹងអនុវត្តច្បាប់ដោយឆន្ទានុសិទ្ធិរបស់ខ្លួនឱ្យបានពេញលេញ។

ជាទូទៅច្បាប់ស្តីពីយុត្តិធម៌អនីតិជនទំនាស់នឹងច្បាប់មានសមាសភាគ ឬ គ្រោង ដូចតទៅ :

- គោលការណ៍ទូទៅ
- យុត្តាធិការ
- អាយុទទួលខុសត្រូវព្រហ្មទណ្ឌ
- ការបង្វែរ (ចេញពីប្រព័ន្ធតុលាការ)

- ការចាប់ខ្លួន ការឃាត់ខ្លួន និង ការស៊ើបសួរ
- ការគ្រប់គ្រងនៅដំណាក់កាលរង់ចាំការជំនុំជំរះ
- ការជំនុំជំរះ
- ការកាត់ទោស
- បទដ្ឋានទាក់ទងនឹងស្ថាប័នដែលឃុំឃាំងឬដាក់អនីតិជន និង ការធ្វើសមាហរណកម្ម
- កំណត់ហេតុឬការកត់ត្រា និង ជីវភាពឯកជន និង
- បញ្ញត្តិផ្សេងៗទៀតទៅតាមស្ថានភាពជាក់ស្តែងរបស់ប្រទេសនីមួយៗ។

សរុបសេចក្តីមក ក្រៅពីត្រូវមានច្បាប់ពិសេស តុលាការឬសភាពិសេស មានឧបករណ៍បែបកុមារមេត្រី ប្រព័ន្ធយុត្តិធមិកុមារត្រូវមានធនធានមនុស្សគ្រប់គ្រាន់ដែលមានឯកទេសច្បាស់លាស់ ដូចជាមេធាវី ចៅក្រម ព្រះរាជអាជ្ញា អ្នកសង្គមកិច្ចឯកទេស និង ត្រូវមានធនធានហិរញ្ញវត្ថុសមរម្យល្មមសំរាប់អនុវត្ត វិធានការច្បាប់ និង វិធានការសុខុមាលភាព។ ក្រៅពីនេះត្រូវមានកម្មវិធីបង្ការអនីតិជនមិនឱ្យប្រព្រឹត្តល្មើស តាំងពីនៅដំណាក់កាលដំបូងនៃជីវិត

ឯកសារពិគ្រោះ :


១– UN Common Approach to Justice for Children, March 2008

២– UN Guidelines on Justice matters involving child victims and witnesses of crime, 2006

៣–Trial Follow-up Child Interviews 2007-2008, IJM

៤- From Legislation to Action ? Trends in Juvenile Justice Across 15 Countries, Defence for Children International, Geneva 2007.

៥- Child Protection Programme Strategy Toolkit, East Asia and Pacific 2007